# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

និយ័តករគណនេយ្យនិងសវនកម្ម
លេខ...០៤៩/២៤...ន. គ. ស/សរ.ជ.ណ.

# សេចក្តីជូនដំណឹង
## ស្តីពី
## សេចក្តីព្រាងឯកសារពិគ្រោះយោបល់លើការស្នើចេញនូវឧទាហរណ៍គំរូពាក់ព័ន្ធនឹងការរាយការណ៍អំពីអាកាសធាតុ និងភាពមិនច្បាស់លាស់ផ្សេងទៀតនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ចេញផ្សាយដោយក្រុមប្រឹក្សាស្តង់ដាគណនេយ្យអន្តរជាតិ

និយ័តករគណនេយ្យនិងសវនកម្ម (**ន.គ.ស.**) សូមជម្រាបជូនដំណឹងដល់គ្រប់សហគ្រាស អង្គភាពមិនស្វែងរកប្រាក់ចំណេញ គណនេយ្យករ សវនករ និងសាធារណជនទូទៅ ឱ្យបានជ្រាបថា៖ នាថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០២៤ ក្រុមប្រឹក្សាស្តង់ដាគណនេយ្យអន្តរជាតិ (International Accounting Standards Board) ដែលជាស្ថាប័នឯករាជ្យក្នុងការអភិវឌ្ឍ និង អនុម័តលើស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ បានចេញផ្សាយនូវសេចក្តីព្រាងឯកសារពិគ្រោះយោបល់លើការស្នើចេញនូវឧទាហរណ៍គំរូពាក់ព័ន្ធនឹងការរាយការណ៍អំពីអាកាសធាតុ និងភាពមិនច្បាស់លាស់ផ្សេងទៀតនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ (Exposure Draft - Climate-related and Other Uncertainties in the Financial Statements-Proposed illustrative examples) ដូចមានភ្ជាប់ជូនខាងក្រោម។

សំណើផ្តល់មតិយោបល់ទៅលើសេចក្តីព្រាងនេះ នឹងផុតកំណត់ត្រឹមថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០២៤។ ដូច្នេះ ប្រសិនបើ សហគ្រាស អង្គភាពមិនស្វែងរកប្រាក់ចំណេញ គណនេយ្យករ សវនករ និងសាធារណជនទូទៅមានបំណងក្នុងការបញ្ចេញមតិយោបល់លើសេចក្តីព្រាងនេះ សូមផ្ញើមតិយោបល់មក **ន.គ.ស.** តាមរយៈអ៊ីម៉ែល៖ c.rachana@acar.gov.kh យ៉ាងយូរត្រឹមថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២៤។

សម្រាប់ព័ត៌មានលម្អិត សូមចូលទៅកាន់គេហទំព័ររបស់និយ័តករ : www.acar.gov.kh។

អាស្រ័យហេតុនេះ សូម សហគ្រាស អង្គភាពមិនស្វែងរកប្រាក់ចំណេញ គណនេយ្យករ សវនករ និងសាធារណជនទូទៅដែលមានតម្រូវការរាយការណ៍ព័ត៌មានខាងលើនេះ ជ្រាបជាព័ត៌មាន។

ថ្ងៃព្រហស្បតិ៍ ១០កើត ខែភទ្របទ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ កញ្ញា គ.ស ២០២៤
**និយ័តករគណនេយ្យនិងសវនកម្ម**

សូមស្កេន QR Code ដើម្បីទាញយកឯកសារ